ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិសន្តិសុខសង្គម
លេខ : ០២៤/២២ ប.ស.ស.

# សេចក្តីជូនដំណឹង
# ស្តីពី
# បន្តការត្រួតពិនិត្យ ដោះស្រាយ ផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ(មានឈីប) សម្រាប់កម្មករនិយោជិត និងសមាជិក ប.ស.ស.

បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) មានកិត្តិយសសូមជម្រាបជូនដំណឹងចំពោះ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងសមាជិក ប.ស.ស. ទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា ដើម្បីជួយសម្របសម្រួលដល់កម្មករនិយោជិត និងសមាជិក ប.ស.ស. ទាំងអស់ដែលគ្មានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងអាចចុះបញ្ជិកានៅ ប.ស.ស. បានទាន់ពេលវេលា ដើម្បីទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗ បេឡាជាតិសន្តិសុខសង្គមបានសហការជាមួយនាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដើម្បីចុះបេសកកម្មសម្របសម្រួល បន្តការ ត្រួតពិនិត្យ ដោះស្រាយ និងផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សម្រាប់កម្មករនិយោជិត និងសមាជិក ប.ស.ស. ដែលគ្មានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។ ដោយឡែកសម្រាប់ទីតាំង ក៏ដូចជាកាលបរិច្ឆេទចុះសម្របសម្រួល និងផ្តល់អត្តសញ្ញាណបណ្ណ ថ្នាក់ដឹកនាំនៃសាខា ប.ស.ស. ខេត្តទទួលបន្ទុកនឹងធ្វើការជូនដំណឹងពេលក្រោយ។

**សូមបញ្ជាក់៖** - **ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរមិនតម្រូវឱ្យបង់ថ្លៃសេវាទេ។**

- **ឯកសារច្បាប់ដើមត្រូវភ្ជាប់មកសម្រាប់ធ្វើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរមានដូចតទៅ៖**

I. **ករណីផ្តល់ថ្មី**

១-សំបុត្រកំណើត រឺសំបុត្របញ្ជាក់កំណើត រឺសេចក្តីចម្លងសំបុត្រកំណើត រឺសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត។

២-សៀវភៅគ្រួសារ(ក៤) រឺសៀវភៅស្នាក់នៅ/សៀវភៅលឿង (ក២) រឺលិខិតបញ្ជាក់ទីលំនៅ។

II. **ករណីផ្តល់ឡើងវិញ**(អាចស្នើសុំថតថ្មីឡើងវិញបានគឺមុនផុតសុពលភាព៩០ថ្ងៃ)

១-សំបុត្រកំណើត រឺសំបុត្របញ្ជាក់កំណើត រឺសេចក្តីចម្លងសំបុត្រកំណើត រឺសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត។

២-សៀវភៅគ្រួសារ រឺសៀវភៅស្នាក់នៅ រឺលិខិតបញ្ជាក់ទីលំនៅ។

៣-អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ច្បាប់ដើម)

III. **ករណីបាត់**

១- ពាក្យបណ្ដឹង (**ឧបសម្ព័ន្ធ១**)

២- ពាក្យស្នើសុំអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរទុតិយតា (**ឧបសម្ព័ន្ធ២**)

៣- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ(ថតចម្លង បើមាន)

IV. **ករណីកែតម្រូវ**( **ខុសបច្ចេកទេស** )

១. អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ច្បាប់ដើម)

២. សេចក្ដីចម្លងសំបុត្រកំណើត រឺសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត

៣. សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ (បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)។

៤. ករណីមានសញ្ញាបត្រ (បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)។

V. **ករណីខូចគុណភាព**

១- អត្តសញ្ញាណបណ្ណខូចគុណភាព(ច្បាប់ដើមរបស់សាមីខ្លួន)។

➘ រាល់ករណីទាំងអស់សូមភ្ជាប់មកជាមួយបណ្ណ ប.ស.ស. ករណីមិនទាន់មានបណ្ណ ប.ស.ស. សូមភ្ជាប់មកនូវលិខិតបញ្ជាក់របស់សហគ្រាស គ្រឹះស្ថាន ដែលកំពុងបំពេញការងារ និងលិខិតបញ្ជាក់ របស់សាខា ប.ស.ស.ខេត្តទទួលបន្ទុក។

➘ ដោយឡែកករណីមានកម្មករនិយោជិត និងសមាជិក ប.ស.ស. ច្រើន សូមធ្វើជាតារាង និងនៅចុងសន្លឹកសូមមានហត្ថលេខារបស់និយោជក និងមានបោះត្រារបស់សហគ្រាស គ្រឹះស្ថាន លើសន្លឹកនីមួយៗ ព្រមទាំងមានការចុះហត្ថលេខាទទួលស្គាល់ដោយ ប្រធាន សាខា ប.ស.ស. ខេត្តទទួលបន្ទុក។

➘ ករណីមានចម្ងល់ទាក់ទងនឹងការសុំផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សូមទំនាក់ទំនងលេខទូរស័ព្ទដែលបានភ្ជាប់ជូនក្នុងតារាង។

បេឡាជាតិសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថា សាខា ប.ស.ស. ខេត្ត ដែលទទួលបន្ទុក និយោជក រឺម្ចាស់សហគ្រាសរឺតំណាងសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងសមាជិក ប.ស.ស. ទាំងអស់ ចូលរួមសហការ ដើម្បីរៀបចំការងារនេះឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២